# កម្មវិធីស្រាវជ្រាវ និងស្វែងយល់អំពីច្បាប់

www.lorkremlaw.wordpress.com

Tel: 012855668 / 069255525


# ក្រមងសំណួរ
# ពាក់ព័ន្ធនៅនឹងរដ្ឋធម្មនុញ្ញ
# នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

**ក្នុងពិធីផ្សព្វផ្សាយរបស់គណៈប្រតិភូក្រុមប្រឹក្សាធម្មនុញ្ញនៅសាលាភូមិន្ទរដ្ឋបាល**

**ថ្ងៃទី០៥ ខែ សីហា ឆ្នាំ២០១០**


*រៀបចំចងក្រងដោយ កម្មវិធីស្រាវជ្រាវ និងស្វែងយល់អំពីច្បាប់*

*រាជធានីភ្នំពេញ ឆ្នាំ២០១៨*

# សំណួរ

## ក. អំពីអធិតេយ្យ

១. នៅមាត្រា ២ បានចែងថា បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបានដាច់ខាតក្នុងព្រំដែនរបស់ខ្លួនដែលមានកំណត់ក្នុងផែនទីខ្នាត ១/១០០.០០០ ធ្វើនៅចន្លោះឆ្នាំ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅចន្លោះឆ្នាំ១៩៦៣-១៩៦៩។ តើការបោះបង្គោលព្រំដែន ដែលកំពុងនឹងបោះជាបន្តបន្ទាប់នៅក្នុងប្រទេសជាប់ភូមិផងរបងជាមួយ តើបានគោរពរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែរ ឬទេ?

២. តើប្រទេសកម្ពុជាបច្ចុប្បន្ន ប្រកាន់យករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ឬអាស្រ័យសភា?

៣. ក្នុងជំពូកទី១ និយាយអំពីអធិតេយ្យ។ សួរថា នៅពេលរដ្ឋសភាបានអនុម័តច្បាប់ដោយសំឡេង ៥០%+១ ប៉ុន្តែក្នុងនោះមានតែគណបក្សតែមួយទេ ដែលមានសំឡេងលើសពី៥០%+១ តើនេះជាការប្រាសចាកពីលទ្ធិប្រជាធិបតេយ្យដែររឺទេ?

## ខ. អំពីព្រះមហាក្សត្រ

១. តាមមាត្រា ២៣ ព្រះមហាក្សត្រទ្រង់ជាមេបញ្ជាការកំពូល នៃកងយោធពលខេមរភូមិន្ទ។ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទត្រូវបានតែងតាំងឡើង ដើម្បីបញ្ជាកងយោធពលខេមរភូមិន្ទនេះ។ មាត្រាខាងលើបានបញ្ជាក់ឲ្យយើងទាំងអស់គ្នាឃើញថា ព្រះមហាក្សត្រទ្រង់មានអំណាចយោធានៅក្នុងដៃ ហើយទ្រង់បានផ្ទេរអំណាចនេះទៅអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ។ សួរថា តើហេតុអ្វីបានជា ព្រះមហាក្សត្រមិនចុះត្រួតពលយោធាជាប្រចាំ ដើម្បីលើកទឹកចិត្តយោធា និងបង្ហាញអំពីអំណាចរបស់ព្រះអង្គ?

២. ព្រះមហាក្សត្រ ត្រូវបានជ្រើសរើសក្នុងចំណោមព្រះរាជបច្ឆាញាតិនៃព្រះមហាក្សត្រអង្គឌួង ឬព្រះមហាក្សត្រនរោត្តម ឬក៏ព្រះមហាក្សត្រស៊ីសុវត្ថិ ហេតុអ្វី?

៣. តើព្រះមហាក្សត្រទ្រង់អាចតែងតាំងអគ្គមេបញ្ជាការនៃកងយុទ្ធពលខេមរភូមិន្ទ ដោយមិនបាច់មានការស្នើសុំពីនាយករដ្ឋមន្ត្រី ឬប្រធានស្ថាប័នណាផ្សេងទៀតបានដែរ ឬទេ ដោយយោងតាមមាត្រា ២៣នៃរដ្ឋធម្មនុញ្ញ។

៤. ហេតុអ្វីបានជាអំណាចព្រះមហាក្សត្រសៀមមានអំណាចខ្លាំងជាង ព្រះមហាក្សត្រកម្ពុជាយើង។ មានមតិខ្លះនិយាយថា នៅពេលដែលព្រះមហាក្សត្រខ្លាំង គេខ្លាចអំណាចនេះទៅជារបបផ្តាច់ការ ចុះហេតុអ្វីនៅប្រទេសសៀមមិនផ្តាច់ការ ហើយប្រជាជនគេគោរពខ្លាំងម្ល៉េះ។

៥. មាត្រា ២៧ តើព្រះមហាក្សត្រអាចលើកលែងទោសដល់បុគ្គលណាម្នាក់ដោយមិនចាំបាច់មានការស្នើសុំពីនាយករដ្ឋមន្ត្រីបានឬទេ?

៦. ហេតុអ្វីបានជាព្រះមហាក្សត្រមិនអាចរំលោភបំពានបាន?

៧. ត្រង់ជំពូកទី២មាត្រា ១០ តើពាក្យ "រជ្ជទាយាទ" និងពាក្យ "រាជ្ជទាយាទ" ខុសគ្នាដូចម្តេច?

៨. នៅក្នុងមាត្រា ៧ ជំពូក២ បានចែងថា «ព្រះមហាក្សត្រកម្ពុជាទ្រង់គ្រងរាជ្យសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ។» ហេតុអ្វីបានជាមាត្រា ២៣ បានចែងថា «ព្រះមហាក្សត្រជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ»?

៩. មាត្រា៧ ចែងថាព្រះមហាក្សត្រកម្ពុជាគ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ។ មាត្រា ព្រះមហាក្សត្រទ្រង់ជាមេបញ្ជាការកំពូលនៃកងយោធពលខេមភូមិន្ទ។ តើមាត្រាពីរនេះ មានលក្ខណៈប្រឆាំងគ្នារឺទេ?

១០.យោងតាមមាត្រា១៤ នៃរដ្ឋធម្មនុញ្ញ តើព្រះរាជវង្សដែលត្រូវជ្រើសរើសជាព្រះមហាក្សត្រត្រូវយកព្រះរាជបច្ឆាញាតិត្រឹមថ្នាក់ទីប៉ុន្មាន?

១១. យោងតាមមាត្រា ២៣ នៃរដ្ឋធម្មនុញ្ញ តើព្រះមហាក្សត្រមានសិទ្ធិដឹកនាំបញ្ជាលើកងយោធពលខេមភូមិន្ទដែរឬទេ?

១២. នៅក្នុងជំពូកទី ២ ត្រង់មាត្រា៧ បានចែងថា "ព្រះមហាក្សត្រទ្រង់គ្រងរាជ ប៉ុន្តែមិនកាន់អំណាច" តើហេតុអ្វីបានជា ទ្រង់អាចជ្រើសរើសសភា ហើយអាចផ្តល់ឯករាជ្យដល់អំណាចតុលាការ?

១៣.ករណីដែលរដ្ឋធម្មនុញ្ញកម្ពុជា មានការកែប្រែធ្វើវិសោធនកម្មជាច្រើនលើកច្រើនសារជាបន្តបន្ទាប់បែបនេះ សូរថា តើវាអាចនិងប៉ះពាល់ដល់គុណតម្លៃនៃធម្មនុញ្ញដើម ឬទេ? សួរថាតើមានមូលហេតុអ្វី បានជារដ្ឋធម្មនុញ្ញកម្ពុជាបានចែងមិនឲ្យកែប្រែលើមាត្រា ៧។

១៤. ហេតុអ្វីបានជាគេថា អំណាចព្រះមហាក្សត្រជាអំណាចជាប់ចំណង?

១៥. សូមអនុញ្ញឯកឧត្តមបកស្រាយនៅមាត្រា ២៣នៃរដ្ឋធម្មនុញ្ញ?

១៦. តាមការបកស្រាយរបស់លោកសាស្ត្រាចារ្យម្នាក់បកស្រាយថា "ព្រះមហាក្សត្រទ្រង់ប្រតិបត្តិអំណាចនីតិប្រតិបត្តិ" តើការបកស្រាយនេះ ឯកឧត្តមយល់យ៉ាងណា? បើក្នុងរដ្ឋធម្មនុញ្ញ មាត្រា៧ចែងថា "ព្រះមហាក្សត្រកម្ពុជាទ្រង់គ្រងរាជតែមិនកាន់អំណាច"។

១៧. ត្រង់ជំពូកទី២មាត្រា ១០ តើពាក្យ រជ្ជទាយាទ និងពាក្យ រាជ្ជទាយាទ ខុសគ្នាដូចម្តេច?

## គ. អំពីសិទ្ធិ និងករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ

១. ជំពូកទី៣មាត្រា ៤៣ ចែងថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ។ចុះហេតុអ្វីបានជាថ្នាក់ដឹកនាំកំពូល នៃក្រសួងធម្មការនិងសាសនាមានរដ្ឋលេខាធិការ និង អនុរដ្ឋលេខាធិការជាសាសនាអ៊ីស្លាមភាគច្រើន?

២. តើមូលហេតុអ្វីបានជាក្រុមប្រឹក្សាធម្មនុញ្ញជាស្ថាប័នកំពូលនៃស្ថាប័នទាំង ៥ នៃព្រះរាជាណាចក្រកម្ពុជា មិនត្រូវបានបញ្ចូលសមាសភាពជាសមាជិកនៃក្រុមប្រឹក្សារាជសម្បត្តិ នៅក្នុងជំពូកទី ២ មាត្រា ១៣៤ នៃរដ្ឋធម្មនុញ្ញ ដែលស្ដីពីការជ្រើសរើសព្រះមហាក្សត្រ?

៣. សូមជួយបកស្រាយ ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ។ ចុះសាសនាដទៃទៀត?

៤. ព្រះមហាក្សត្រត្រូវបានជ្រើសរើសក្នុងចំណោមព្រះរាជបច្ឆាញាតិនៃ ព្រះមហាក្សត្រ អង្គឌួង ឬព្រះមហាក្សត្រ នរោត្តម ឬក៏ព្រះមហាក្សត្រស៊ីសុវត្ថិ ហេតុអ្វី?

៥. ក្នុងមាត្រា៣២(ជំពូក ៣)ចែងថា «ទោសប្រហារជីវិតមិនត្រូវឲ្យមានឡើយ»។ ខ្ញុំស្នើឯកឧត្តមមេត្តាជួយផ្ដល់ហេតុផលខ្លះៗ ទាក់ទងការមិនឲ្យមានទោសប្រហារជីវិតនេះ។ ចុះប្រសិនបើយើងចែងឲ្យមានទោសប្រហារជីវិតវិញ តើវាអាចមានផលប៉ះពាល់អ្វីខ្លះ?

៦. តើអ្វីទៅដែលហៅថា «សញ្ជាតិខ្មែរពីកំណើត»? តើបុគ្គលណាម្នាក់ដែលសុំចូលជាសញ្ជាតិខ្មែរ អាចឈរឈ្មោះឲ្យគេបោះឆ្នោតជាតំណាងរាស្ត្របានឬទេ?

៧. តើអ្វីទៅហៅថា ការបោះឆ្នោតសកល និងការបោះឆ្នោតជាអសកល?

៨. តើការបោះឆ្នោតសកល និងអសកលមានលក្ខណៈខុសគ្នាត្រង់ណា?

៩. នៅក្នុងមាត្រា ៤៣ ព្រះពុទ្ធសាសនារបស់រដ្ឋ ហើយព្រះសង្ឃមានសិទ្ធិបោះឆ្នោតតំណាងរាស្ត្របាន តើព្រះសង្ឃសិទ្ធិនយោបាយបានឬទេ?បើបានមូលហេតុអ្វី បើមិនបានមូលហេតុអ្វី?

១០. សូមឲ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ៣៣ ត្រង់វាក្យខ័ណ្ឌទី១ និង ទី២។ ហេតុអ្វីចាំបាច់មាន កិច្ចព្រមព្រៀងជាមួយបរទេសក្នុងការចាប់បញ្ជូលជនជាតិខ្មែរឲ្យទៅបរទេស បើប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅបរទេសត្រូវបានរដ្ឋគាំពារ។

១១. មាត្រា៣ "......" ប្រជាពលរដ្ឋធម្មនុញ្ញខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ចដែលមានចែងក្នុងច្បាប់។

១២. ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ បើតាមគោលការណ៍សមភាព តើមានការប៉ះពាល់ដល់សាសនាដទៃទៀតឬទេ?

## គ. អំពីរបបនយោបាយ

១. ពន្យល់ពាក្យ អាវុធវេគ្រាណូ។

២. មាត្រា ៥១ថ្មី នៃរដ្ឋធម្មនុញ្ញចែងថា «អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការ។» សួរថា តើស្ថាប័ន ឬអង្គនីតិបញ្ញត្តិ និងតុលាការ អាចស្ថិតនៅក្រោមអង្គនីតិប្រតិបត្តិ ឬរដ្ឋាភិបាលដែរឬទេ?

៣. ចូរពន្យល់អំពីអំណាចទាំងបី បែងចែកដាច់ពីគ្នា គឺ អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ?

៤. តើរដ្ឋធម្មនុញ្ញខ្មែរជារដ្ឋធម្មនុញ្ញទន់នេះ មានផលប៉ះពាល់ដល់ប្រព័ន្ធច្បាប់ និងនយោបាយដែរ ឬទេ?

៥. បើប្រទេសកម្ពុជាត្រូវបានឈ្លានពានដោយប្រទេសណាមួយ ហើយប្រទេសកម្ពុជាបានដាក់នៅក្នុងភាពអាសន្ន។ នៅក្នុងរដ្ឋធម្មនុញ្ញមិនឲ្យធ្វើវិសោធនកម្មក្នុងពេលមានអាសន្ន ហើយមិនឲ្យផលិត និងប្រើប្រាស់នូវប្រភេទអាវុធដូចមានចែងក្នុងមាត្រា៥៤ជំពូកទី៤។ ប្រទេសដែលឈ្លាន ពានប្រទេសកម្ពុជាគេមាននូវប្រភេទអាវុធទាំងនោះ។ ក្នុងគោលបំណងការពារបូរណភាពដឹកដីប្រទេសកម្ពុជាត្រូវការនូវអាវុធទាំងនោះ និងមានលទ្ធភាពក្នុងផលិតដើម្បីប្រើប្រាស់ តើត្រូវធ្វើដូចម្តេចធម្មនុញ្ញរបស់ខ្លួនបិទផ្លូវតវ៉ាយ៉ាងនេះ?

## ខ. អំពីសេដ្ឋកិច្ច

១. សូមជួយពន្យល់ពាក្យៈ "រូបបវន្តបុគ្គល" "នីតិបុគ្គល" និង "ភោគោសាស្ត្រ" ។

២. មាត្រា៥៨ ចែងថា «ទ្រព្យសម្បត្តិរបស់រដ្ឋមាន...ភ្នំ...ឆ្នេរសមុទ្រ...។»ប៉ុន្តែជាក់ស្តែងនៅខេត្ត ព្រះសីហនុឃើញមានភ្នំត្រូវបានគេសង់លំនៅដ្ឋាន និងតំបន់ឆ្នេរសមុទ្រមួយចំនួនត្រូវបានហ៊ុំព័ទ្ធជាទ្រព្យសម្បត្តិឯកជន។ សូមមេត្តាជួយបកស្រាយ?

## ច. អំពីការអប់រំ វប្បធម៌ និងសង្គមកិច្ច

១. ជំពូកទី៦ អំពីអប់រំ វប្បធ៌ម និងសង្គមកិច្ច មាត្រា ៦៥ រដ្ឋយកចិត្តទុកដាក់វិស័យអប់រំកាយ និងកីឡា ដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប(និង កិត្យានុភាពជាតិ)។ ដើម្បីជំរុញវិស័យអប់រំកាយ និង

កីឡា គួរបញ្ចូលសកម្មភាពកីឡាក្នុងកម្មវិធីប្រលងរបស់សិស្ស-និស្សិត។ តើរដ្ឋបានគិតអំពីការកសាងហេដ្ឋារចនាសម្ព័ន្ធកីឡា កំរិតណាហើយ?

២. មាត្រា ៧១ ចែងថា «បរិវេណបេតិកភ័ណ្ឌជាតិ ក៏ដូចជាបេតិកភ័ណ្ឌដែលបញ្ចូលជាបេតិកភ័ណ្ឌពិភពលោក ត្រូវទុកជាតំបន់អព្យាក្រឹត្យដែលមិនអាចមានសកម្មភាពយោធា។» ជាក់ស្តែងនៅតំបន់ប្រាសាទព្រះវិហារមានសកម្មភាពយោធាយ៉ាងគគ្រឹកគគ្រេង។ តើសកម្មភាពយោធានេះ ធ្វើឲ្យប៉ះពាល់ដល់មាត្រា ៧១ នេះដែរឬទេ?

៣. តើនៅពេលរដ្ឋាភិបាលសម្រេចអនុញ្ញាតផ្តល់ការវិនិយោគទៅឲ្យក្រុមហ៊ុនឯកជនមួយ យកលុយលើផ្លូវជាតិ តើប៉ះពាល់ដល់រដ្ឋធម្មនុញ្ញដែលធានាដល់សិទ្ធិដើរហើរលើផ្លូវជាតិដោយសេរីដែរ ឬទេ?

៤. ករណីជាក់ស្តែង កម្ពុជាទាក់ទងនឹងប្រាសាទព្រះវិហារដែលបានបញ្ចូលជាបតិកភ័ណ្ឌពិភពលោក រួចហើយដោយមានសកម្មភាពយោធានោះ តើមានការប៉ះពាល់ដល់មាត្រា ៧១ នៃរដ្ឋធម្មនុញ្ញកម្ពុជាដែរឬទេ?

## ឆ. អំពីរដ្ឋសភា

១. មាត្រា ៩០ ថ្មី(ពីរ) វាក្យខណ្ឌទី៥ បានចែងថា រដ្ឋសភាអនុម័តយល់ព្រម ឬ លុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ។ កន្លងមកតើហេតុអ្វីបានជារដ្ឋសភាមិនចាំបាច់អនុម័តលើការព្រមជាមុន ទៅលើកិច្ចព្រមព្រៀងអន្តរជាតិមួយចំនួន ដូចជា OMU ជាដើម ដោយត្រឹមតែរាជរដ្ឋាភិបាលជាអ្នកសំរេច និងយល់ព្រម និងចុះហត្ថលេខា និងមិនចាំបាច់ឆ្លងកាត់សភា? តើអនុសញ្ញា សន្ធិសញ្ញា ឬ កិច្ចព្រមព្រៀងអន្តរជាតិកំរិតណាត្រូវចាំបាច់សុំការយល់ព្រម ពីរដ្ឋសភា និង កំរិតណាត្រឹមរាជរដ្ឋាភិបាលជាអ្នកសំរេច?

២. មាត្រា ៨២ថ្មី ចែងថា "រដ្ឋសភាបើកសម័យប្រជុំដំបូងហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ" ចុះបើស្ថានភាពនយោបាយមិនអំណោយផលធ្វើឲ្យលើសរយៈពេលហុកសិបថ្ងៃទើបរដ្ឋសភាប្រជុំដំបូងបាន តើបញ្ហាផ្លូវច្បាប់ទៅយ៉ាងណា?

៣. ក្រៅពីរដ្ឋសភា និងព្រឹទ្ធសភា តើស្ថាប័នណាទៀតដែលមានអភ័យឯកសិទ្ធិសភា?

៤. មាត្រា៧៧ វាក្យខណ្ឌទី២ ចែងថា «អណត្តិអាជ្ញាបញ្ជាទាំងឡាយត្រូវទុកជាមោឃៈ» តើមាន ន័យដូចម្តេច?

៥. តើមតិភាគច្រើនដោយប្រៀប និងមតិភាគច្រើនដាច់ខាតមានន័យខុសគ្នាយ៉ាងណា?

៦. ច្បាប់រៀបចំអង្គការ ត្រូវតែបញ្ជូនឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពមុននឹងប្រកាសឲ្យប្រើ ចុះបើរដ្ឋសភាមិនបញ្ជូន ឬក៏ភ្លេចបញ្ជូនមកពិនិត្យធម្មនុញ្ញភាព តើច្បាប់នោះមានសុពលភាពដើម្បីអនុវត្តដែរឬទេ?

៧. នៅក្រោយពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រម្តងៗ តែងតែមានបញ្ហារឿងកូរ៉ុមសម្រាប់ប្រជុំដំបូងរដ្ឋសភា ហើយតែងតែមានការបកស្រាយផ្សេងៗពីគ្នារវាងអ្នកច្បាប់ ក៏ដូចជាអ្នកនយោបាយ ដែលមាននិន្នាការនយោបាយផ្សេងគ្នា តើបញ្ហានេះក្រុមប្រឹក្សាធម្មនុញ្ញយល់យ៉ាងណា?

៨. ពាក្យថា វិសមភាពនឹងមុខងារមានន័យដូចម្តេច?

៩. តើអ្នកណាខ្លះដែលអាចទទួលអភ័យឯកសិទ្ធិ?

១០. អត្ថន័យមាត្រា ៧៧ អាណត្តិអាជ្ញាបញ្ជាទាំងឡាយត្រូវទុកជាមោឃៈ?

១១. សភាធម្មនុញ្ញ និងរដ្ឋសភា មានន័យដូចម្តេច? សូមជួយពន្យល់។

១២. តើការកំណត់សមាជិករដ្ឋសភា ផ្អែកលើកត្តាមូលដ្ឋានអ្វីខ្លះ?

១៣. មាត្រា៧៨នៃជំពូកទី៧ ចែងថា "នីតិកាលរបស់រដ្ឋសភាមានអាណត្តិ៥ឆ្នាំ..............." ជានីតិវិធី តើនាយករដ្ឋមន្ត្រីត្រូវតែស្នើរំលាយរដ្ឋសភាក្រោយរដ្ឋាភិបាលត្រូវទំលាក់២ដងរយៈពេល១២ខែ ឬយ៉ាងណា? តើនឹងត្រូវមានដំណោះស្រាយយ៉ាងណាប្រសិនបើប្រធានរដ្ឋសភាមិនយល់ព្រមរំលាយរដ្ឋសភា?

## ៥. អំពីព្រឹទ្ធសភា

១. តើសមាជិកព្រឹទ្ធសភា ២រូប ដែលត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និង២រូបទៀតដោយ រដ្ឋសភាជ្រើសតាំងមានឋានៈជាអ្វី?

២. ចូរពន្យល់ថាតើព្រឹទ្ធសភា ជួយសម្របសម្រួលអ្វីខ្លះរវាងរដ្ឋសភា និងរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា?

៣. ក្នុងរដ្ឋធម្មនុញ្ញចែងថា "រដ្ឋសភា និងព្រឹទ្ធសភាមានថវិកាស្វយ័តសម្រាប់ដំណើរការ"តែរដ្ឋសភា និងព្រឹទ្ធសភាមិនមែនជា ស្ថាប័នប្រមូលចំណូលទេ។ ហើយក្នុងន័យសេដ្ឋកិច្ចពាក្យថា រកលុយខ្លួនឯង ចាយខ្លួនឯង។ សូមអនុញ្ញាតក្រុមប្រឹក្សាធម្មនុញ្ញមេត្តាបកស្រាយ។

៤. ស្ថាប័នព្រឹទ្ធសភា រដ្ឋសភា និង ក្រុមប្រឹក្សាធម្មនុញ្ញ មូលហេតុអ្វីបានជាបង្កើតច្រើនដូច្នេះ? តើមានដំណើរការយ៉ាងដូចម្តេចដែរ(តួនាទី)។

## ឈ. អំពីអំណាចតុលាការ

១. សូមមេត្តាបកស្រាយវាក្យខណ្ឌទី៣នៃមាត្រា១២៩ថ្មី នៃរដ្ឋធម្មនុញ្ញស្តីពី "អំណាចតុលាការគ្រប ដណ្តប់ទៅលើរឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផង"។ ជាងដប់ឆ្នាំមកហើយ ដែលព្រះរាជាណាចក្រកម្ពុជាទីពីរបានចាប់បដិសន្ធិ ខ្ញុំបាទពុំដែលលឺតុលាការកម្ពុជាកាត់ក្តីរដ្ឋបាលទេ តើមកពីបញ្ហាអ្វីខ្លះ? តើរយៈពេលជាងដប់ឆ្នាំនេះ ពុំមានរឿងក្តីរដ្ឋបាលឬមួយយ៉ាងណា? បើមាន តើមានក្រុមប្រឹក្សាធម្មនុញ្ញមានវិធានអ្វីខ្លះដល់ស្ថាប័នតុលាការ?

២. តើគម្រោងបង្កើតតុលាការតាមផ្នែកនៅពេលខាងមុខរបស់រាជរដ្ឋាភិបាល ដូចជា តុលាការពាណិជ្ជកម្មតើតម្រូវឲ្យធ្វវិសោធន៍កម្មរដ្ឋធម្មនុញ្ញ មាត្រា១២៨ថ្មី ដែរឬទេ? ដោយមាត្រានេះពុំបានបែងចែកឲ្យដាច់ពីតុលាការតាមផ្នែកនោះទេ ក្នុងការជម្រះរឿងក្តី។

៣. សូមមេត្តាជួយបកស្រាយនូវមាត្រា ១២៨ថ្មី វាក្យខណ្ឌទី១ ចែងថា «អំណាចតុលាការជាអំណាចឯករាជ្យ» តើខុសគ្នាជាមួយអព្យាក្រឹត្យភាពរបស់ចៅក្រមយ៉ាងដូចម្តេច?

៤. តើនៅពេលចៅក្រមបានប្រព្រឹត្តអំពើពុករលួយ និងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ អាចត្រូវគេដកហូតពីតំណែងឬទេ?

## ញ. អំពីក្រុមប្រឹក្សាធម្មនុញ្ញ

១. ក្រៅពីការធានាការគោរពរដ្ឋធម្មនុញ្ញ ការពិនិត្យរដ្ឋធម្មនុញ្ញ...។ តើក្រុមប្រឹក្សាធម្មនុញ្ញ មានអំណាចអាទិភាពឬបុព្វសិទ្ធិផ្សេងទៀតឬទេ? ក្នុងការសំរេចជោគវាសនាប្រទេសជាតិឧទាហរណ៍ដូចជាការ សំរេចឲ្យធ្វើសង្គ្រាម ឬ មិនធ្វើសង្គ្រាមជាដើម?

២. តើក្រុមប្រឹក្សាធម្មនុញ្ញ មានឥទ្ធិពលលើអង្គការនីតិប្រតិបត្តិដែរឬទេ? ហើយក្រុមប្រឹក្សាធម្មនុញ្ញមានអន្តរទំនាក់ទំនងគ្នាយ៉ាងដូចម្តេចជាមួយរាជរដ្ឋាភិបាល?

៣. តើរដ្ឋធម្មនុញ្ញកម្ពុជាជារដ្ឋធម្មនុញ្ញ រឹង ឬ ទន់? តើយើងដឹងតាមរយៈមធ្យោបាយអ្វី?

៤. ក្រុមប្រឹក្សាធម្មនុញ្ញបានដំណើរការណ៍នៅឆ្នាំ ១៩៩៨ ចំនែករដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣ សូមសួរ ថា តើយើងមានយន្តការអ្វីដើម្បីធានាការការពាររដ្ឋធម្មនុញ្ញមុនបង្កើតក្រុមប្រឹក្សានេះ?

៥. សូមធ្វើអធិប្បាយអំពីនិមិត្តសញ្ញារបស់ក្រុមប្រឹក្សាធម្មនុញ្ញ មានន័យដូចម្តេច? ដើម្បីអ្វី?

៦. តើក្រុមប្រឹក្សាធម្មនុញ្ញ ដោះស្រាយវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា (ស្របតាមមាត្រា ១៣៦ថ្មី នៃរដ្ឋធម្មនុញ្ញ) ក្នុងដំណាក់កាលណាខ្លះ?

៧. អំពើអាណត្តិរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ហេតុអ្វីបានជាមាន ៣ឆ្នាំ ៦ឆ្នាំ ៩ឆ្នាំ និង១២ឆ្នាំ សូមឲ្យឧទាហរណ៍ជាក់ស្តែង។

៨. ជិតដល់ពេលបោះឆ្នោតព្រឹទ្ធសភា រដ្ឋសភាទៀតហើយ តើក្រុមប្រឹក្សាធម្មនុញ្ញត្រៀមលក្ខណៈបែបណា?

៩. ក្រុមប្រឹក្សាធម្មនុញ្ញជាស្ថាប័នកំពូល តើប្រធាននិងសមាជិកស្មើអ្វី? ហេតុអ្វីក្រុមប្រឹក្សាធមនុញ្ញគ្មានអនុប្រធាន?

១០. មាត្រា ៥១ថ្មី ចែងថា "អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ" តើក្រុមប្រឹក្សាធម្មនុញ្ញស្ថិតក្នុងអំណាចណាមួយខាងលើ?

១១. ក្រុមប្រឹក្សាធម្មនុញ្ញដោះស្រាយវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភាលើ គ.ជ.ប។ តើក្រុមប្រឹក្សាធម្មនុញ្ញមានអំណាចឋានានុក្រមលើ គ.ជ.ប ដែរឬទេ? ហេតុអ្វីបានជានៅពេលបោះឆ្នោតម្តងៗ ប្រជាពលរដ្ឋ និងមន្ត្រីរាជការមួយចំនួនមិនសូវស្គាល់សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញដូចស្គាល់ គ.ជ.ប ទេ ដែលជាហេតុធ្វើឲ្យពួកគាត់បាត់សិទ្ធិមួយចំនួន។

១២. ប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានសំឡេងឧត្តមានុភាព ក្នុងករណីសំឡេងបែកជាពីរស្មើគ្នា(មាត្រា១៣៧ថ្មី)។ តើមានន័យដូចម្តេច?

១៣. នៅពេលដែលក្រុមប្រឹក្សាធម្មនុញ្ញសម្រេចថា ច្បាប់ ឬសេចក្តីព្រាងណាមួយផ្ទុយរដ្ឋធម្មនុញ្ញហើយ។ តើក្រុមប្រឹក្សាធម្មនុញ្ញគ្រាន់តែធ្វើសេចក្តីសម្រេចបញ្ជាក់ អធម្មនុញ្ញភាពជាការស្រេច ឬត្រូវឲ្យរដ្ឋសភា ឬព្រះមហាក្សត្រចេញព្រះរាជក្រមថ្មីបញ្ជាក់ពីអធម្មនុញ្ញនោះ?

១៤. តើអ្នកណាខ្លះមានសិទ្ធិធ្វើការបកស្រាយច្បាប់?

១៥. ខ្ញុំបាទសង្កេតឃើញថា ក្នុងព្រះរាជក្រមប្រកាសឲ្យប្រើច្បាប់ ដែលច្បាប់មួយចំនួន តួយ៉ាងរួមមាន ច្បាប់ភូមិបាលឆ្នាំ២០០១ ច្បាប់ជលផលឆ្នាំ២០០៦ និងក្រមរដ្ឋប្បវេណីឆ្នាំ២០០៦ ពុំឃើញមានការឆ្លងការពិនិត្យធម្មនុញ្ញភាព និងប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ប៉ុន្តែមានឆ្លងក្រុមប្រឹក្សាធម្មនុញ្ញចំពោះច្បាប់អស្សាមិករណ៍ ឆ្នាំ២០១០។ តើហេតុអ្វីបានជាច្បាប់ខ្លះត្រូវឆ្លងនិងមានច្បាប់ខ្លះមិនអាចឆ្លងកាត់ក្រុមប្រឹក្សាធម្មនុញ្ញ?

១៦. ខ្ញុំធ្លាប់លឺពាក្យថា ក្រុមប្រឹក្សាធម្មនុញ្ញជានិយ័តករនៃអំណាចទាំងបី សូមឯកឧត្តម ជួយពន្យល់ថា ហេតុអ្វីបានជាគេអាចនិយាយថាក្រុមប្រឹក្សាធម្មនុញ្ញជានិយ័តករ?

១៧. បើសិនក្នុងរយៈពេល ៣០ថ្ងៃ ក្រុមប្រឹក្សាធម្មនុញ្ញធ្វើសេចក្តីសម្រេចមិនទាន់ តើមានអ្វីកើតឡើង? អាចពន្យាពេលបានឬទេ?

១៨. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ អាចជាកម្មវត្ថុនៃការបកស្រាយជាលើកទី២ ដែរឬទេ?

១៩. តើក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចដោះស្រាយវិវាទច្បាប់ដែរឬទេ?

២០. តើប្រធានក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើអ្វី? សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានឋានៈស្មើអ្វី? និង អគ្គលេខាធិការនៃក្រុមប្រឹក្សាធម្មនុញ្ញមានឋានៈស្មើអ្វី?

២១. តើសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានអភ័យឯកសិទ្ធិដូចអ្នកតំណាងរាស្ត្រដែរឬទេ? បើសមាជិកណាម្នាក់បានប្រព្រឹត្តបទល្មើស តើនីតិវិធីចោទប្រកាន់ប្រព្រឹត្តទៅយ៉ាងដូចម្តេច?

២២. តាមច្បាប់ការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់របស់ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាមានលក្ខណៈ ពិសេសជាងក្រុមប្រឹក្សាធម្មនុញ្ញបារាំងបន្តិចត្រង់ថា យើងមានការត្រួតពិនិត្យជាមុន និងការត្រួតពិនិត្យជាក្រោយ។ដោយឡែកបារាំងមានតែការត្រួតពិនិត្យជាមុន មានន័យថាមុនច្បាប់ចូលជាធរមាន។ ដូច្នេះតើនឹងមានផលវិបាកដែរ ឬទេ? ប្រសិនបើច្បាប់មួយបានចូលជាធរមានរួចហើយ ប្រជាជនអនុវត្តជាប្រចាំថ្ងៃហើយ តែត្រូវក្រុមប្រឹក្សាធម្មនុញ្ញប្រកាសអធម្មនុញ្ញភាពទៅវិញ។

២៣. តើក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចត្រួតពិនិត្យលើច្បាប់ធម្មនុញ្ញបន្ថែមដែរឬទេ? បើមាន ឬគ្មានដោយសារមូលហេតុអ្វីខ្លះ?

២៤. ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិក ប្រាំបួនរូប ទទួលអាណត្តិប្រាំបួនឆ្នាំ តើហេតុអ្វីបានជាសមាជិកទាំងប្រាំបួនរូបត្រូវបានតែងតាំង ឬជ្រើសតាំងផ្សេងៗគ្នា? មានបីរូបដោយព្រះមហាក្សត្រ បីរូបដោយរដ្ឋសភា បីរូបដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម?

២៥. ចំពោះពាក្យថា "ក្រុមប្រឹក្សា"និងពាក្យ "សភា" ពាក្យនេះមានន័យប្រហាក់ប្រហែលគ្នា។ ឧទាហរណ៍ ក្រុមប្រឹក្សារដ្ឋ។ តើពាក្យថា "សភាធម្មនុញ្ញ" និងក្រុមប្រឹក្សាធម្មនុញ្ញខុសគ្នាយ៉ាងដូចម្តេច?

២៦. អ្នកសួរទី៧៨ នៅក្នុងជំពូកទី២ ត្រង់មាត្រា៧ បានចែងថា "ព្រះមហាក្សត្រទ្រង់គ្រងរាជ ប៉ុន្តែមិនកាន់អំណាច "ចូរពន្យល់?

២៧. តើហេតុអ្វីបានជា ទ្រង់អាចជ្រើសរើសសភា ហើយអាចផ្តល់ឯករាជ្យដល់អំណាចតុលាការ ?

២៨. នៅពេលក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាពនៃច្បាប់ណាមួយ គេយករដ្ឋធម្មនុញ្ញជាគោល។ នៅពេលក្រុមប្រឹក្សាបកស្រាយមាត្រាណាមួយនៃរដ្ឋធម្មនុញ្ញ តើគេយកអ្វីធ្វើជាឯកសារគោល ?

២៩. តើក្រុមប្រឹក្សាធម្មនុញ្ញមួយអាណត្តិមានរយពេលប៉ុន្មានឆ្នាំ ?

៣០. ជំពូកទី១២ថ្មីមាត្រា១៣៦ចែងថា "ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចការពារគោរពរដ្ឋធម្មនុញ្ញ បកស្រាយធម្មនុញ្ញ និង ច្បាប់ដែលសភាបានអនុម័ត" នៅក្នុងករណីដែលច្បាប់ផ្ទុយពីស្មារតីរដ្ឋធម្មនុញ្ញ តើក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិស្នើទៅសភាឲ្យមោឃភាពច្បាប់នោះបានទេ ?

៣១. ក្រុមប្រឹក្សាធម្មនុញ្ញក៏ជាស្ថាប័នកំពូលមួយរបស់ប្រទេសដែរ ហេតុអ្វីបានជាមិនធ្វើការជ្រើសរើសដោយការបោះឆ្នោត ជាសាកល ?

៣២. តើអ្វីទៅ ដែលហៅថា ការបកស្រាយច្បាប់ ?

៣៣. តើស្ថាប័នណាខ្លះមានសិទ្ធិបកស្រាយច្បាប់ក្រៅពីក្រុមប្រឹក្សាធម្មនុញ្ញ ?

៣៤. ក្រុមប្រឹក្សាធម្មនុញ្ញមានទំនាក់ទំនង និងកិច្ចសហប្រតិបត្តការលើឆាកអន្តរជាតិកំរិតណា ?

## ៨. អំពីសមាជជាតិ

១. រដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាមានចែងក្នុងជំពូកទី១៤ អំពីសមាជាតិ។ តើសមាជាតិអាចរៀបចំដំណើរការនៅពេលណា ?

២. ហេតុអ្វីបានជាយើងមិនដែលធ្វើសមាជជាតិ ?

៣. ជំពូកទី១៤ថ្មី នៃរដ្ឋធម្មនុញ្ញចែងអំពីសមាជជាតិ ដែលជាវេទិកាបើកទូលាយឲ្យប្រជារាស្ត្រចូលរួម និងជួបដោយផ្ទាល់ជាមួយនឹងថ្នាក់ដឹកនាំជាតិទៅលើបញ្ហា និងកង្វល់របស់ជាតិ។រហូតដល់ពេលនេះមិនទាន់មានសមាជជាតិ បើកសម្រាប់ប្រជារាស្ត្រលើកអំពីកង្វល់របស់ពួកគាត់ដើម្បីដោះស្រាយ។ តើថា ការចែងរបស់រដ្ឋធម្មនុញ្ញចំពោះជំពូកខាងលើ និងការដែលមិនអនុវត្តរដ្ឋធម្មនុញ្ញជាច្បាប់កំពូលរបស់ប្រទេសជាតិនេះ មានផលប៉ះពាល់ឬទេ ?

៤. មាត្រា ១៤៨ថ្មី ចែងថា "សមាជជាតិប្រជុំមួយដងក្នុងមួយឆ្នាំនៅដើម ខែធ្នូ តាមការកោះអញ្ជើញរបស់នាយករដ្ឋមន្ត្រី"។ ហេតុអ្វីមកដល់ពេលនេះ សមាជជាតិមិនអាចដំណើរការបាន ?

៥. តើយើងគួរលុបមាត្រា ១៤៨ថ្មី ដែរឬទេ? ព្រោះថាប្រទេសយើងមិនដែលយកអនុវត្តន៍។

៦. ហេតុអ្វីក៏មិនមានសមាជរៀងរាល់ឆ្នាំ ទៅតាមរដ្ឋធម្មនុញ្ញ?

## ៥. អំពីអានុភាព ការសើរើ និងវិសោធនកម្មធម្មនុញ្ញ

១. ករណីដែលរដ្ឋធម្មនុញ្ញកម្ពុជា មានការកែប្រែធ្វើវិសោធនកម្មជាច្រើនលើកច្រើនសារជាបន្តបន្ទាប់បែបនេះ សួរថា តើវាអាចនិងប៉ះពាល់ដល់គុណតម្លៃនៃធម្មនុញ្ញដើមរឺទេ? សួរថាតើមានមូល ហេតុអ្វីបានជារដ្ឋធម្មនុញ្ញកម្ពុជាបានចែងមិនឲ្យកែប្រែលើមាត្រា ៧ ។

២. ហេតុដូចម្តេចបានជា រដ្ឋសភាធ្វើវិសោធនកម្មមាត្រាខ្លះៗ ឲ្យតែបង្កើតរដ្ឋសភាថ្មី?

៣. តើការធ្វើវិសោធនកម្មមាត្រាមួយចំនួននៃច្បាប់រដ្ឋធម្មនុញ្ញ ធ្វើឲ្យប៉ះពាល់ដល់ច្បាប់មួយចំនួនដែលនៅក្រោមឬទេ?

## ៦. អំពីអន្តរប្បញ្ញត្តិ

១. សូមមេត្តាពន្យល់នូវមាត្រា ១៥៨ថ្មី នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ ឧទាហរណ៍ ច្បាប់ភូមិបាលឆ្នាំ២០០១ ត្រូវបានអនុម័តដើម្បីកែប្រែច្បាប់ភូមិបាលឆ្នាំ១៩៩២។ តើច្បាប់ភូមិបាលឆ្នាំ១៩៩២ អាចនៅមានប្បញ្ញត្តិមួយចំនួនអនុវត្តបានដែរ ឬទេ ប្រសិនបើច្បាប់ភូមិបាលឆ្នាំ២០០១ ពុំបានចែង។

**រៀបចំចងក្រងដោយ**

**កម្មវិធីស្រាវជ្រាវ និងស្វែងយល់អំពីច្បាប់**

www.lorkremlaw.wordpress.com